# រឿង
# ម៉ាក់ទាំងពីររបស់ខ្ញុំ
## MY PARENTS ARE WOMEN

ភុយ រតនា
អៀម សំណាង



# ម៉ាក់ទាំងពីររបស់ខ្ញុំ (My parents are women)

**Written by** Phuy Rathana
**Artwork by** Eam Samnang

**Co-Editors** Sai Yee Tip,
Prak Monirath,
Uoeung Bonsovathary

**Art Editor** San Somanear

**Reviewed by** Khmer Youth Association (KYA),
Love is Diversity

Publisher Khmer Youth Association (KYA)
No. 32D, St. 562, Phnom Penh12151, Cambodia

Copyright © 2024 by Khmer Youth Association (KYA)

All rights reserved.
Without limiting the rights under the copyright reserved above, no part of this publication may be reproduced, stored in or introduced into a retrieval system, or transmitted, in any form, or by any means (electronic, mechanical, photocopying, recording, or otherwise), without the prior written permission of the copyright owner.
Published in Phnom Penh, Cambodia.

A catalog record for this book is available from
the National Library of Cambodia
ISBN: 978-9924-9966-3-7

Disclaimer: This storybook is made possible by the generous support of the American people through the United States Agency for International Development (USAID)-funded Civil Society Support (CSS) Activity implemented by Family Health International (FHI360). The contents are the responsibility of Khmer Youth Association and do not necessarily reflect the views of USAID or the United States Government.

# រឿង

# ម៉ាក់ទាំងពីររបស់ខ្ញុំ

# MY PARENTS ARE WOMEN







ពួកគេទាំងពីរនាក់ធ្វើការនៅគ្រឹះស្ថានតែមួយ




«អេសុភា នេះឯងបានសៀវភៅថ្មីអានទៀតហើយ អ្អេស? ឱ្យគ្នាសុំមើលបន្តិចបានទេ?» ណៃដារ និយាយ និងឈោងដៃទៅប៉ះសៀវភៅសុភា។
នែ នរណាអនុញ្ញាតឱ្យ ឯងប៉ះរបស់យើង?
តើខ្ញុំខុសអី ហេតុអីបានជាឯង ស្អប់ខ្ញុំបែបនេះ?
ឯងខុស គឺខុសដោយសារមាន ឪពុកម្តាយដែលជាមនុស្សស្រីដូចគ្នា គឺជាគ្រួសារដែលខុសពីគេ


តាំងពីតូចមកណែដារ
មិនសូវមានផ្លូវចិត្ត
រឹងមាំប៉ុន្មាននោះទេ។
លុះធំដឹងក្ដីឡើងនៅ
ក្នុងគ្រួសារដែលខុស
ប្លែកពីគេទៀតធ្វើឱ្យ
នាងទទួលបានការ
រើសអើង ភាពស្អប់ខ្ពើម
និងការមាក់ងាយ។
មិនតែប៉ុណ្ណោះមិត្តរួម
ថ្នាក់នាងក៏មិនសូវមាន
នរណាចង់រាប់អាន
នាងនោះដែរ។
នេះថ្នាក់ខ្ញុំជាកូនរបស់គាត់ គេមាក់ងាយ មើលស្រាលប៉ុណ្ណឹង ចុះទម្រាំម៉ាក់ខ្ញុំវិញ?
តើមនុស្សជុំវិញខ្លួនគាត់មើលឃើញគាត់ជាមនុស្សចម្លែកដូចសុភាមើលឃើញខ្ញុំដែរ ឬទេ?
ផ្ទះណែដារ


ណៃជឿន៖
ណៃដាវកូន អើយណៃដាវមកញុំាបាយជុំគ្នា
មិនឃើញណៃដាវតបនឹងណៃជឿនឡើយ។
តុក
តុក
(ស្ទាត់)
(តុក)
(តុក)
(ក្រាក....)
ទ្វាបើកលេចវត្តមានណៃដាវមកទាំងមុខហើមហាក់ដូចជាទើបនឹងយំរួចថ្មីៗ
ហេតុអីណៃដាវចម្លែកម្ល៉េះថ្ងៃនេះ? កាលពីល្ងាចមិញពេលមកដល់ផ្ទះក៏ស្ងាត់មិនឃើញមាត់ករកអូនសោះ
ប្រហែលជារឿងដដែលហ្នឹងឯង
តើពេលណាទៅហ្ន៎ ទើបសង្គមនេះនឹងព្រមបើកចិត្តឱ្យទូលាយទទួលយកធម្មជាតិរបស់ក្រុមមនុស្ស ដូចជាពួកយើង?
ណៃជឿន៖
ប្រាកដជាអាច គ្មានអ្វីដែលមិនអាចទៅរួចទេនៅលើលោកនេះ គ្រាន់តែ... ត្រូវការពេលវេលាបន្តិចប៉ុណ្ណោះ។



កើតអីហ្នឹង កូនយំមែនទេ?
កុំគិតច្រើនអីកូន បន្តិចទៀតអ្វីៗនឹងល្អប្រសើរជាងនេះជាមិនខាន
តើបន្តិចទៀតនោះជាពេលណាទៅម៉ាក់?
ផាន់ណាហុចដៃទៅប៉ះស្មាណៃដារហើយតប៖
គឺពេលមួយដែលមនុស្សមានភាពយល់ដឹងពីទំនាក់ទំនងរបស់ក្រុមមនុស្សដូចជាពួកម៉ាក់ណាំកូន
បាសម៉ាក់
ដឹងថាក្រុមមនុស្សដែលស្រលាញ់ភេទដូចគ្នាក្តីភេទផ្ទុយគ្នាក្តីសុទ្ធសឹងតែមានមនោសញ្ចេតនា ការគោរព ការតស៊ូ និងការលះបង់ដូចៗគ្នា។ ហើយពួកម៉ាក់គ្រាន់តែសង្ឃឹមថ្ងៃនោះនឹងមកដល់ឆាប់ៗប៉ុណ្ណោះ


ណៃជាវដើរចូលក្នុងថ្នាក់ដូចសព្វមួយដងសភាពក្នុងថ្នាក់ គឺប្រក្រតីតែអ្វីដែលមិនប្រក្រតីនោះគឺជាតាដែលជាមិត្តរួមថ្នាក់របស់ណៃជាវញញឹម និងដើរសំដៅមករកនាង
ជាតា៖
ណៃជាវតស់ទៅបណ្ណាល័យជាមួយពួកយើងទេ ម៉ោងនេះលោកគ្រូគណិតអត់បានមកបង្រៀនទេ
ណៃជាវ៖
ចាស?
ពិតជាចម្លែកណាស់ ព្រោះរាល់ដងជាតាគឺជាម្នាក់ក្នុងចំណោមមិត្តរួមថ្នាក់ដទៃដែលស្អប់ រើសអើង និងចូលចិត្តធ្វើបាបណៃជាវជាងគេបង្អស់។
ឱកាសល្អមកដល់ ជាតា និងបក្សពួករុញណៃជាវមួយទំហឹងចូលទៅក្នុងបណ្ណាល័យ
ចាក់
គន្លឹះទ្វារភ្លាម
(ធម្មតាបណ្ណាល័យនេះគ្មានបណ្ណារក្សនៅមើលនោះទេ ព្រោះក្នុងសាលាខ្វះគ្រូ ទើបនាយិកាសាលាបើកទ្វាចោល សម្រាប់ឱ្យសិស្សចូលអានពេលទំនេរ។)
បើកទ្វាៗ ហ៊ឺៗ ពួកឯងធ្វើអីហ្នឹង ហ៊ឺ...


ក្នុងទីចាត់ការ
អ្នកណាជាអ្នកផ្ដើមគំនិតនេះឡើង?
គឺជាតាអ្នកគ្រូ
គឺ... គឺ
គឺខ្ញុំ...ខ្ញុំស្អប់ណែដាវអ្នកគ្រូ...
ហេតុអីបានជាពួកកូនធ្វើបែបនេះ? កូនដឹងទេថាវាជាទង្វើមិនល្អ មិន សមក្មេងៗដូចជាកូនប្រព្រឹត្តដែរទេ?
គឺមកពីណែដាវមិនដូចជាអ្នកដទៃអ្នកគ្រូ
ស្អប់? ហេតុអីកូនស្អប់គេ? គេបានធ្វើអ្វីកូនមែនទេ?
មិនដូចគេ? មិនដូចយ៉ាងម៉េច?
ព្រោះគ្រួសារគេគឺចម្លែកមិន ដូចជាគ្រួសារអ្នកដទៃទេអ្នកគ្រូ
នាយិកាដោះវ៉ែនតាទុកនៅលើតុ ហើយយកដៃឈ្លីក្បាលខ្លួនឯងបន្តិចមុននឹង មានប្រសាសន៍តបទៅនឹងជាតាវិញ និងបន្ថយសំឡេងរបស់គាត់បន្តិច


នាយិកា៖
កូនដឹងទេថាទង្វើនេះគឺខុសខ្លាំងណាស់ ការរើសអើង ការស្អប់ខ្ពើមចំពោះអ្នកដទៃគឺមិនគួរមានទាល់តែសោះក្នុងសាលារៀនបែបនេះ។ រឹតតែមិនគួរកើតឡើងចេញពីក្មេងៗដែលមានការអប់រំ និងជាទំពាំងស្នងឫស្សីដូចជាពួកកូន
ឱ្យពួកខ្ញុំសុំទោសអ្នកគ្រូ...
កើតមកក្នុងគ្រួសារបែបណាជាកូនរបស់អ្នកណា ណៃដារក្តី ឬក៏កូនក្តីមិនអាចរើសកំណើតបានទេ
នាយិកាលើកដៃអង្អែលស្មារបស់ណៃដារដែលអង្គុយជិតខ្លួនគាត់ថ្នមៗ ដើម្បីលួងលោមណៃដារ
អ្នកគ្រូសង្ឃឹមរឿងបែបនេះនឹងមិនកើតឡើងវិញម្តងទៀតនោះទេ
ចាស អ្នកគ្រូ
នាយិកា៖
ណៃដារកើតក្នុងគ្រួសារ ដែលមានអាណាព្យាបាលបែបនេះជាមនុស្សស្រីដូចគ្នាបែបនេះក៏មិនមែនជាកំហុសនោះដែរ។


នាយិកា៖
សម័យនេះគឺជាសតវត្សទី២១ហើយ ជាសម័យជឿនលឿនមនុស្សមានសិទ្ធិសេរីភាពធំទូលាយជាងមុនឆ្ងាយណាស់។ ហើយចំពោះរឿងបែបនេះក៏ជារឿងធម្មតាទៅហើយចំពោះប្រទេសមួយចំនួននៅលើសកលលោកនេះ។ ក្រុមមនុស្សទាំងនេះក៏ដូចជាមនុស្សធម្មតាដែរ ពួកគេគប្បីទទួលបានការលើកទឹកចិត្ត និងការទទួលស្គាល់ពីមនុស្សជុំវិញខ្លួនរបស់គេ។ តើកូនយល់ដែរទេ?
ឯងដូចជាខ្លាំងពេកហើយណែដារ។ បើទោះជាយើងមិនហ៊ានធ្វើអីដាក់ឯងទៀតក៏ពិតមែន តែឯងកុំសង្ឃឹមឱ្យសោះថាយើងនឹងចាត់ទុកឯងជាម្នាក់ក្នុងចំណោមមិត្តរបស់យើងនោះ។
តើខ្ញុំខុសខ្លាំងណាស់មែនទេជាតា?
មែនហើយ ឯងខុសដែលកើតក្នុងគ្រួសារខុសគេ
តើខ្ញុំបានសាងកម្មអីពីជាតិមុន? ហេតុអីបានជាជាតិនេះរស់នៅក្នុងសេចក្ដីស្អប់ខ្ពើម និងរើសអើងពីអ្នកដទៃបែបនេះ?

នាងទទួលបានទូរស័ព្ទពីនាយិកាសាលា ប្រាប់ពីរឿងរ៉ាវដែលបានកើតឡើងចំពោះណៃដាវក្នុងថ្ងៃនេះ តែដោយសារនៅកន្លែងការងាររវល់ពេកទើបណៃឌឿន និងផាន់ណាមិនអាចទៅមើលកូននៅសាលាភ្លាមៗបាន។




និយាយចប់ណៃឌឿន និងផាន់ណាសម្លឹងមុខគ្នាទាំងទឹកមុខស្រងូតស្រងាត់


ពេលយប់/ក្នុងបន្ទប់ណៃជឿន និងផាន់ណា
អូនដឹងថាបងចង់និយាយពីអ្វី
ផាន់ណា...
រហូតដល់ដង្ហើមអូនឈប់ដកយើងបានចាប់ដៃគ្នាជាមួយគ្នាមកដល់ពេលនេះហើយ គឺមិនងាយទ្បើយ
ណៃជឿន៖
បងក៏ដូចគ្នា តែចុះកូនណៃដាវ?
ក្នុងនាមជាអាណាព្យាបាល យើងត្រូវមើលថែទាំ ផ្ដល់ការស្រលាញ់ដល់គេ លើកទឹកចិត្ត និងជួយជំរុញគេឱ្យចេះឈរដោយខ្លួនឯងយ៉ាងរឹងប៉ឹង
បងសង្ឃឹមថាកូនស្រីរបស់យើងនឹងអាចធ្វើវាបាន
សំឡេងទូរស័ព្ទរបស់ផាន់ណារោទ៍ឡើង កាត់ផ្ដាច់ពេលវេលាដ៏តានតឹងនេះ...
**«អាឡូបងផាន់ណា...ហ៊ឺៗ...»** សំឡេងរបស់ផាន់ណែតបន្លឺឡើងពីខ្សែម្ខាងទៀត


មកដល់មន្ទីរពេទ្យផាន់ណាឈរយំឱបប្អូនស្រី ពេលដឹងថាម្ដាយកំពុងតែនៅក្នុងបន្ទប់វះកាត់។
ម៉ាក់យ៉ាងម៉េចហើយអូន? ហ៊ឺៗ...
ផាន់ណា និងផាន់ណែតបានត្រឹមតែបន់ស្រន់ឱ្យការវះកាត់បានជោគជ័យ ហើយម្ដាយរួចផុតពីគ្រោះថ្នាក់ប៉ុណ្ណោះ។ នៅក្នុងស្ថានការណ៍ដ៏លំបាកនេះ ណៃដឿននៅក្បែរ និងជួយលើកទឹកចិត្តផាន់ណារហូត។
បង ម៉ាក់ធ្លាយខ្នែងពោះវៀន ពេទ្យក៏បញ្ជូនគាត់ចូលវះកាត់បន្ទាន់តែម្ដង ហ៊ឺៗ...
IN OPERATION
IN OPERATION
២ម៉ោងក្រោយមក/ក្នុងមន្ទីរពេទ្យ
ចូលរួមអបអរសាទរផង អ្នកជំងឺផុតពីគ្រោះថ្នាក់ហើយ
លោកគ្រូពេទ្យ ម៉ាក់របស់ខ្ញុំយ៉ាងម៉េចហើយ?
អរ..អរគុណលោកគ្រូពេទ្យណាស់
បន្ទាប់ពីថ្ងៃវះកាត់ខ្នែងពោះវៀនដល់លោកស្រីផល្លារួចមកផាន់ណា និងណៃដឿនតែងតែមកមើលថែម្ដាយមិនដែលដាច់ពេលមួយណាឡើយ។


ណែដាវក្រោយពេលចេញពីសាលារៀន នាងតែងតែមកមន្ទីរពេទ្យជាមួយម្ដាយ ដើម្បីជួយមើលថែលោកយាយដែរ។
ណែដឿន និងផាន់ណាដើរចូលមកតាមក្រោយដែរ ដោយមានកាន់ស្បោងផ្លែឈើមកជាមួយផង។ ក្រោយរៀបចំផ្លែឈើរួច ណែដាវក៏ចិតផ្លែឈើបញ្ចុកលោកយាយទាំងរីករាយ។
លោកយាយ
អរគុណចៅ
លោកស្រីផល្លាកំពុងតែញ៉ាំសុខៗ លោកយាយស្រាប់តែភ្ញើក
អឹកៗ... ផាន់ណាជួយយកទឹកឱ្យម៉ាក់បន្តិច
ពេលឮសម្ដីម្ដាយភ្លាមផាន់ណាក៏ញញឹមហើយក៏ប្រញាប់យកទឹកជូនម្ដាយ។ លោកស្រីផល្លាក៏ទទួលយកទឹក ដោយមានស្នាមញញឹមមកជាមួយផង។

ក្រោយពីសម្រាកព្យាបាល នៅមន្ទីរពេទ្យបាន១០ថ្ងៃ លោកស្រីផល្លាក៏ប្រែរឹងមាំឡើងវិញយ៉ាងឆាប់រហ័ស អាចមកពីការព្យាបាលបានល្អរួមផ្សំជាមួយការមើលថែទាំពីក្រុមគ្រួសារបានដិតដល់ផង។ ថ្លៃព្យាបាលជំងឺក៏មានចំណែករបស់ផាន់ណានិងណែដឿនចូលរួមមួយផ្នែកធំផងដែរ។ ថ្ងៃនេះគ្រូពេទ្យអនុញ្ញាតឱ្យលោកស្រីផល្លាចេញពីមន្ទីរពេទ្យត្រឡប់ទៅផ្ទះវិញបានហើយ។ ផាន់ណែតកំពុងរៀបចំអីវ៉ាន់ យូរៗម្ដងលោកស្រីផល្លាក៏អើតមើលទៅកាន់ទ្វារបន្ទប់។




ថ្ងៃនេះក៏មិនខុសពីថ្ងៃមុនណែដឿន និងផាន់ណានាំ
ណែដារមកលេងជាមួយលោកយាយ ព្រមទាំងយករបស់
ដែលលោកស្រីផល្លាចូលចិត្តមកផងដែរ។
ក្នុងផ្ទះលោកស្រីផល្លា
លោកស្រីផល្លាស្រលាញ់ចៅស្រីរបស់គាត់ណាស់។ ហើយពេលនេះគាត់ក៏ហាក់លែង
ស្អប់ខ្ញើមកូនស្រីទៀតដែរ។ គាត់មិនបាននិយាយ តែទង្វើគាត់ក៏ប្រាប់មកបែបហ្នឹង។
មើលទៅក្ដីស្រលាញ់បរិសុទ្ធរបស់អ្នកទាំងពីរយកឈ្នះចិត្តម្ដាយបានសម្រេចហើយ។
ណែដារ៖
ពួកអ្នកម៉ាក់កុំពិបាកចិត្តនឹងរឿងកូនច្រើនពេកអី
ណែដឿនឧទានព្រោះមិនទាន់ចាប់បានថាណែដារចង់សំដៅលើអ្វី។


សុំទោសថ្ងៃមុនកូនឮអ្នកទាំងពីរនិយាយ
គ្នាដោយចៃដន្យអំពីរឿងរបស់កូន។ ម៉ាក់
ដឹងទេ ពីមុនកូនធ្លាប់អន់ចិត្តពិតមែន។
ណែដាវ៖
កូនតែងតែគិតថាតើកូនធម្មតាដូចគេឯងទេដែលមានម្ដាយជាស្រីទាំងពីរ
នាក់បែបនេះ? តើនេះជាបាបកម្មរបស់កូនដែលត្រូវលុបលាងមែនទេ?
កូនធ្លាប់តែខូចចិត្តពេលគេនិយាយថាឱ្យកូនបែបនេះបែបនោះ តែ
ពេលនេះកូនយល់ពីម៉ាក់ទាំងពីរហើយទំនាក់ទំនងរបស់ម៉ាក់ពិតជាបរិសុទ្ធ
ណាស់ក្ដីស្រលាញ់ដែលម៉ាក់ផ្ដល់ឱ្យគ្នាផ្ដល់ឱ្យលោកយាយផ្ដល់ឱ្យកូន
គឺធំធេងណាស់ គេផ្សេងបានការស្រលាញ់ពីម្ដាយតែម្នាក់ តែកូន...កូន
ទទួលបានពីម្ដាយដល់ទៅពីរនាក់ម៉ាក់ថាមើលទៅមិនអស្ចារ្យទេ? ចាប់ពី
ថ្ងៃនេះទៅកូននឹងរឹងមាំជាងនេះ កូននឹងធ្វើឱ្យគេឃើញថាកូនមានសំណាង
ដែលមានម៉ាក់ជាម៉ាក់។
ចុះលោកយាយវិញគិតយ៉ាងម៉េចដែរ?
នៅខឹងម៉ាក់ចៅទៀតទេលោកយាយ?


លោកស្រីផល្លា៖ «ញញឹម»
យាយឈប់ខឹងម្ដាយចៅតាំងពីពេលណាក៏មិនដឹង
អីចឹងមានតែស្រលាញ់មែនទេលោកយាយ?
លោកស្រីផល្លា៖ «ញញឹម»
ក៏ស្រលាញ់...តែមិនមែនស្រលាញ់តែម្នាក់ទេ គឺទាំងពីរនាក់
អរគុណម៉ាក់!
ទាំងពីរនាក់ស្រវាឱបម្ដាយទាំងរំភើប។ ផាន់ណែតដែលនៅក្បែរលោកយាយមើលបងស្រី និងម្ដាយដោយក្ដីពេញចិត្ត។

ណៃដាវចេញពីសាលាដូចសព្វដងនៅតាមផ្លូវស្រាប់តែមាននារីម្នាក់ដួលសន្លប់នៅក្បែរផ្លូវ។ ណៃដាវផ្តួលកង់ហើយរត់ទៅជួយនារីម្នាក់នោះភ្លាម។




ឡានពេទ្យមកដល់សហការីបានលើកនារីម្នាក់នោះដាក់លើឡានភ្លាមៗ។ «តើក្មួយអាចឡើងឡានទៅជាមួយពួកយើងបានទេ?» ណៃដាវដោយបារម្ភពីនារីម្នាក់នោះផង នាងក៏ឡើងឡានពេទ្យទៅជាមួយ។


នៅបន្ទប់មន្ទីរពេទ្យសម្រាកព្យាបាល
បងស្រីធ្លាក់ចុះជាតិស្ករកម្រិតធ្ងន់ធ្ងរទើបបណ្ដាលឱ្យងងឹតមុខដួលសន្លប់បែបនេះ។ ហើយការធ្លាក់ចុះជាតិស្ករធ្ងន់ធ្ងរពេកនេះអាចឈានដល់ការបាត់បង់ស្មារតី និងអាចឈានដល់ការស្លាប់បាត់បង់ជីវិតផងក៏មាន សំណាងណាស់ដែលបានក្មួយស្រីទូរស័ព្ទហៅឡានពេទ្យ និងបញ្ជូនមកទីនេះទាន់ពេល បងស្រីជំពាក់គុណក្មួយស្រីម្នាក់នេះហើយ។
ខ្ញុំអរគុណលោកគ្រូពេទ្យណាស់
មីងអរគុណក្មួយខ្លាំងណាស់ ដែលជួយសង្គ្រោះជីវិតមីងដូច្នេះ បើគ្មានក្មួយទេ មីងប្រហែលជាយ៉ាប់មិនខាន
ចា៎ មិនអីទេមីង ជួយគ្នាទៅវិញទៅមកគឺជារឿងត្រឹមត្រូវ ដែលគប្បីនឹងធ្វើ
ក្មួយពិតជាក្មេងល្អ និងក្លាហានពិតមែន បើមីងជាម៉ាក់ក្មួយ មីងពិតជាមានមោទនភាពខ្លាំងណាស់ដែលមានក្មួយស្រីជាកូន
មួយសន្ទុះក្រោយមកជាតា និងឪពុករបស់នាងរត់ចូលមកយ៉ាងត្រហេបត្រហប សំដៅទៅអ្នកជំងឺទាំងទឹកមុខភិតភ័យ។
ម៉ាក់! ម៉ាក់មិនអីទេមែនទេ?
ម៉ាក់លែងអី ហើយកូន
!


ជាតាញញឹមចូលក្បែរម្តាយខ្លួន។ តែនាងភ្ញាក់ព្រើតចំពោះវត្តមានណៃដាវ
កំពុងនៅជាមួយម្តាយដែរ។
ណៃដាវក៏ភ្ញាក់ផ្អើលមិនតិចដែរ មិននឹកស្មានថាចៃដន្យនារីដែលនាងបានជួយសង្គ្រោះ
គឺជាម្តាយរបស់ជាតា ជាមនុស្សដែលតែងតែធ្វើបាបនាងនៅសាលារៀនកន្លងមក។
ណៃដាវកូន
យ៉ាងម៉េចហើយ?
កូនមិនបាន
កើតអីទេម៉ាក់



គ្រួសារទាំងពីរបានជួបគ្នា









**ជាតា៖**
ចុងក្រោយឯងគឺជា អ្នកជួយសង្គ្រោះជីវិតម៉ាក់របស់យើង

**ណៃដារ៖**
ឯងមានអារម្មណ៍យ៉ាងម៉េចដែរ?

**ជាតា៖**
យើងភ័យណាស់ ភ័យខ្លាចម៉ាក់មានរឿងអីធ្ងន់ធ្ងរជាងនេះ

**ណៃដារ៖**
ឯងស្រលាញ់ម៉ាក់ឯងខ្លាំងណាស់មែនទេជាតា?

**ជាតា៖**
ត្រូវហើយ យើងក៏ដូចគ្នាដែរ យើងស្រលាញ់ម៉ាក់យើងខ្លាំងណាស់ ឯងដឹងទេថាក្តីស្រលាញ់ម្តាយចំពោះកូនធំធេងប៉ុនណានោះ? ក្តីស្រលាញ់ម្តាយចំពោះកូនគឺបរិសុទ្ធណាស់។

**ណៃដារ៖**
យើងពិតជាសំណាងដែលបានកើតជាកូនរបស់ម៉ាក់យើងទាំងពីរ។ យើងទទួលបានក្តីស្រលាញ់ពេញបរិបូណ៌ពីពួកគាត់ដូចជាឯងអីចឹង។ យើងទាំងពីរមិនខុសគ្នាទេ យើងក៏មិនមែនចម្លែកដែរ ហេតុអីបានជាឯងស្អប់ខ្ពើម ធ្វើបាបយើង គ្រាន់តែឪពុកម្តាយយើងជាមនុស្សស្រីដូចគ្នាប៉ុណ្ណឹងនោះ?


ម្ដាយទាំងពីររបស់ណៃដាវភ្ញាក់ផ្អើលនៅពេលដែលដឹងថានារី ដែលកូនគាត់បាន ជួយសង្គ្រោះ គឺជាម្ដាយក្មេងដែលធ្វើបាបកូនគាត់នៅសាលារៀន។
ជាតា៖
យើង...យើងសុំទោសណៃដាវ សុំទោសដែលមិនធ្លាប់មើលឃើញ តម្លៃឯងសុំទោសដែលស្អប់ឯង ធ្វើបាបឯង។ ចុងក្រោយអ្នកដែល យើងធ្វើបាបគឺជាអ្នកជួយម៉ាក់យើង ទៅវិញ។ យើងពិតជាសុំទោស។
មិនអីទេឱ្យតែឯងយល់ យើងសប្បាយចិត្តហើយ
ឪពុកម្ដាយជាតាអរគុណ និងសុំទោសដល់ណៃដាវ ម្ដងទៀតមុនពេលពួកគេលាចេញពីមន្ទីរពេទ្យ
ហើយអរគុណ ដែលជួយជីវិតម៉ាក់យើង


ថ្ងៃនេះនៅក្នុងថ្នាក់រៀនរបស់ណៃដារ អ្នកគ្រូបានឱ្យសិស្សទាំងអស់លេងល្បែងមួយមុននឹងចូលមេរៀនថ្មី។
DING
DING
DING
(School Break Bell)
គាត់បានចាប់ក្រុមឱ្យសិស្ស ក្នុងមួយក្រុមមានគ្នាពីរនាក់ ដើម្បីសម្ភាសន៍គ្នាទៅវិញទៅមកអំពីគ្រួសាររបស់ដៃគូក្រុមពួកគេ និងសរសេរដាក់ក្រដាសដើម្បីអានឱ្យមិត្តក្នុងថ្នាក់បានស្ដាប់។
2
ចៃដន្យជាតា និងណៃដារគឺត្រូវបានដាក់ក្នុងក្រុមជាមួយគ្នា។
១៥នាទីក្រោយមកអ្នកគ្រូបានប្រាប់ឱ្យសិស្សទាំងអស់គ្នាអង្គុយជារង្វង់ និងចាប់ក្រុមដែលត្រូវងើបអានសំណេរដែលបានសម្ភាសន៍ពីដៃគូរួចឱ្យមិត្តរួមថ្នាក់បានស្ដាប់ ក្នុងនោះអ្នកគ្រូក៏ចាប់ប៉ះក្រុមណៃដារ និងក្រុមរបស់សុភា។

ជាតាកើតមកក្នុងគ្រួសារដែលមានជីវភាពមធ្យមមួយ។
ប៉ារបស់នាងរាល់ថ្ងៃ គឺរវល់នឹងការងារណាស់ ប៉ុន្តែគាត់
មិនដែលភ្លេចកូន និងប្រពន្ធឡើយ។ ជាតាទទួលបានក្ដី
ស្រលាញ់ពីម៉ាក់ និងប៉ារបស់នាងដូចជាគ្រួសារទូទៅដែរ។



ណៃដារកើតក្នុងគ្រួសារដែលមានម្ដាយពីរនាក់។ នាងទទួល
បានក្ដីស្រលាញ់យ៉ាងពេញលេញពីម្ដាយទាំងពីររបស់នាង។
នាងលែងទន់ជ្រាយ អន់ចិត្តនឹងគ្រួសារនាងទៀតហើយ
ព្រោះគ្រួសារនាង និងគ្រួសារអ្នកដទៃមិនខុសគ្នាទេ គឺមានក្ដី
ស្រលាញ់ចំពោះកូន ដូចគ្នាទៅនឹងគ្រួសារអ្នកដទៃដែរ។



សុភាជាកូនអាជីវករនៅផ្សារម្នាក់។ ឪពុកម្ដាយគាត់ពិតជារវល់
ណាស់ ហើយជារៀងរាល់ថ្ងៃគេមិនសូវមានពេលជាមួយប៉ាម៉ាក់
គេឡើយ។ សុភាបានរៀនសូត្រ មានអាហារហូបចុក និងលុយ
ចាយគ្រប់គ្រាន់តែអ្វីដែលគេចង់បាននោះគឺពេលវេលាពីប៉ាម៉ាក់
របស់គេ។



បញ្ញាជាក្មេងដែលកើតមកពុំបានឃើញមុខឪពុកម្ដាយឡើយ។
គេរស់នៅ ជំពាត់ជាមួយនឹងជីដូនរបស់គេ ហើយទទួលបាន
ក្ដីស្រលាញ់ពីជីដូន តែគេពិតជាចង់ស្គាល់ពីក្ដីស្រលាញ់របស់
ឪពុកម្ដាយថាតើវាបែបណា?



ក្រោយពីប្អូនស្តាប់សំណេរអំពីក្រុមគ្រួសាររបស់អ្នកទាំងបួនហើយ
ប្អូនឃើញទេថាស្ថានភាពគ្រួសាររបស់គ្រប់គ្នាគឺខុសៗគ្នា តែអ្វីមួយ
ដែលដូចគ្នានោះ គឺក្តីស្រលាញ់។ ក្នុងសង្គមជាក់ស្តែង អ្នកខ្លះក៏មាន
ឪពុកម្តាយទាំងពីរ អ្នកខ្លះមានម្តាយទាំងពីរនាក់ អ្នកខ្លះមានឪពុក
ទាំងពីរនាក់ អ្នកខ្លះមានតែម្តាយ អ្នកខ្លះមានតែឪពុក រីឯអ្នកខ្លះក៏គ្មាន
ទាំងម្តាយ និងឪពុក រស់ជាមួយសាច់ញាតិដទៃ។

ទោះបីជាកើតមកមានម្តាយទាំងពីរនាក់ ឬឪពុកទាំងពីរនាក់ក្តី ក៏ពួកគេ
មិនខុសគេដែរ។ ពួកគេគឺជាគ្រួសារមួយពេញលេញដូចគ្រួសារដទៃ
អីចឹង ព្រោះតែមានក្តីស្រលាញ់ ដែលបង្កើតបានជាពាក្យថា គ្រួសារ។
ក្នុងសកម្មភាពនេះ អ្នកគ្រូចង់បង្ហាញពួកប្អូនៗថា ទោះកើតក្នុង
ស្ថានភាពគ្រួសារបែបណាក៏ដោយ ក៏ពួកគេមានសិទ្ធិពេញលេញក្នុង
ការរស់នៅជាមួយពួកយើង។

ពួកគេមិនគួរទទួលបានការរើសអើង មាក់ងាយព្រោះតែគេមានប៉ាម៉ាក់
ភេទដូចគ្នា ឬក៏គ្មានប៉ាម៉ាក់នោះឡើយ។




ណៃដារ
ណៃដារ យើងមកនេះគឺយើងចង់មកសុំទោសឯង
អរគុណឯងម្តងទៀតដែលបានជួយម៉ាក់យើង។ យើងដឹងថាពួកយើងធ្លាប់យល់ខុស ធ្លាប់ធ្វើខុសលើឯង។ វាគឺជាទង្វើមិនគប្បីនឹងកើតឡើងពីក្មេងសិស្សសាលាដូចជាពួកយើងសោះ គឺក្មេងដែលទទួលបានការអប់រំ ពេលនេះយើងបានយល់ហើយថាគ្រួសាររបសណៃដារមិនខុសពីគេទេ ពួកយើងទេដែលខុស ហើយខុសដែលធ្វើបាប និងរើសអើងដល់ឯងទាំងដែលឯងគ្មានកំហុសអ្វីទាល់តែសោះ


ណែដារ យើងមកនេះគឺ យើងចង់មកសុំទោសឯង
តើណែដារអាចលើកលែងឱ្យ ពួកយើងបានទេ?
បើអីចឹង... ចាប់ពីថ្ងៃនេះទៅ តើពួកយើង អាចក្លាយជាមិត្តនឹងគ្នាបានដែរទេ?
ប្រាកដជាបាន
*ណែដារងក់ក្បាលជាមួយ ស្នាមញញឹមជំនួសចម្លើយ។

ក្រោយភ្លៀង មេឃស្រឡះ ក្រោយមានរឿងរ៉ាវជាច្រើនបានកើតឡើងចំពោះគ្រួសារណៃដាវ នាងបានរៀនពីមេរៀនជីវិតជាច្រើនទាំងវ័យក្មេង ដែលមិនមានបង្រៀននៅក្នុងសាលា។ ណៃដាវធ្លាប់តែជាក្មេងដែលមានផ្លូវចិត្តទន់ខ្សោយ ខ្លាចអ្នកដទៃ មិនសូវក្លាហាន តែពេលនេះប្រែហើយ ណៃដាវជ្រួតជ្រាបពីក្តីស្រលាញ់របស់ម្តាយ គ្រប់ពេលដែលនាងនៅជាមួយលោកយាយ នាងតែងឃើញម្តាយទាំងពីរធ្វើល្អ និងស្រលាញ់លោកយាយណាស់ ទោះលោកយាយមិននិយាយរក ឬមិនទទួលស្គាល់ពួកគាត់ក៏ដោយ។






ឃើញទង្វើទាំងអស់របស់ម្តាយ បានជំរុញទឹកចិត្តណៃដាវឱ្យប្រែជាមានភាពក្លាហាន លែងតូចចិត្តនឹងវាសនាខ្លួនឯងតទៀត ចេះជួយអ្នកដទៃ ម្ចាស់ការលើខ្លួនឯងជាងមុន។ ចាប់ពីថ្ងៃនោះមកណៃដាវចាប់ផ្តើមមានមិត្តរាប់អានបណ្តើរៗយ៉ាងច្រើន។ ការរើសអើង និងការធ្វើបាបលើរូបនាងក៏លែងកើតមានទៀតនៅក្នុងថ្នាក់ទី ៩«ខ»។ មួយនេះទៀតដែរ ពេលពួកគេបានរាប់អាន និងចូលចិត្តណៃដាវ ទើបគេដឹងថានាងជាមនុស្សល្អ និងគួរឱ្យរាប់អានខ្លាំងប៉ុណ្ណា។ យើងមិនអាចរើសកន្លែងកើតបានទេ រឹតតែមិនអាចរើសបានថាចង់កើតជាមនុស្សប្រុស ឬមនុស្សស្រី។ កើតមកជាភេទអ្វីសុទ្ធតែមានតម្លៃ និងសិទ្ធិសេរីភាពដូចៗគ្នា៕

ISBN: 978-9924-9966-3-7